**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១០៨៩ ព.ណ.ក.ណ.ម

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២៤

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន សឺង ជី បាង អ៊ិនវេសម៉ិន ឯ.ក**

**កម្មវត្ថុ:** លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក 赛力斯 និង **SERES** លើរថយន្ត និងគ្រឿងបន្លាស់រថយន្តរបស់ក្រុមហ៊ុន **សឺង ជី បាង អ៊ិនវេសម៉ិន ឯ.ក** ដែលមានម៉ូឌែលភ្ជាប់ជាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **សឺង ជី បាង អ៊ិនវេសម៉ិន ឯ.ក** ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៩៤៤៩១/២៤ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៩៤៤៩២/២៤ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ជូនលោក/លោកស្រីប្រធានជ្រាបថា តាមរយៈការចុះបញ្ជីម៉ាកដែលមានលេខចុះបញ្ជី KH/៩៤៤៩១/២៤ និង KH/៩៤៤៩២/២៤ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនរបស់លោក/លោកស្រីបានទទួលសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ ដូចមានចែងក្នុងមាត្រា ៣ និងមាត្រា ១១ នៃច្បាប់ដែលបានយោងខាងលើនេះ។

លិខិតបញ្ជាក់នេះ មានសុពលភាព ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវអស់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ក្នុងករណីដែលការចុះបញ្ជីម៉ាកត្រូវបានបាត់បង់សុពលភាពដោយប្រការណាមួយនោះ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

**អ៊ុក-ប្រជា**

*ចម្លងជូន:*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ-កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# បញ្ជី

## ម៉ូដែលឆ្លាប់ និងលិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ

## រថយន្ត

| ល.រ | ឈ្មោះ ម៉ូដែល |
| --- | --- |
| 1 | SERES M5 |
| 2 | SERES M7 |
| 3 | SERES M8 |
| 4 | SERES M9 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
**ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

# កំណត់បង្ហាញ
## ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

**កម្មវត្ថុ** ៖ សំណើសុំបញ្ជាក់សិទ្ធិផ្តាច់មុខម៉ាក 赛力斯 និង **SERES** ក្នុងការនាំចូល និងចែកចាយលើផលិតផលគ្រឿងបន្លាស់រថយន្ត របស់ក្រុមហ៊ុន **សឹង ជី បាវ អ៊ិនវេសម៉ិន ឯ.ក**

**អ្នកស្នើសុំ** ៖ ក្រុមហ៊ុន **សឹង ជី បាវ អ៊ិនវេសម៉ិន ឯ.ក**

**ខ្លឹមសារ** ៖ ☑ មានលិខិតស្នើសុំបញ្ជាក់សិទ្ធិផ្តាច់មុខ
☑ មានឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុនក្នុងស្រុក
☑ មានឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកនេះ។
ដូច្នេះ លិខិតប្រគល់សិទ្ធិផ្តាច់មុខមានទម្រង់អាចអនុញ្ញាតឱ្យធ្វើការកត់ត្រាបាន ដោយផ្តល់រយៈពេលមានសុពលភាព៖
☑ ២ឆ្នាំ
☐ តិចជាង ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ដល់ថ្ងៃទី ខែ ឆ្នាំ

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាននាយកដ្ឋាន ឯកឧត្តមអគ្គនាយក** និង **ឯកឧត្តមរដ្ឋលេខាធិការ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

**ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

22.02.24

**លុយ សុផល្លា**

| **យោបល់របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកសេវាពាណិជ្ជកម្ម** | **យោបល់អនុប្រធាននាយកដ្ឋាន** |
|---|---|
| [illegible]<br>26.3.24<br>**ម៉ុម ថាណា** | **គោរពជូន**<br>យោងមាត្រា៣ និង១១ នៃច្បាប់ម៉ាក និងឯកសារតម្រូវដែលបានដាក់មកនាងខ្ញុំ/ខ្ញុំបាទយល់ឃើញថា ក្រសួងអាចអនុញ្ញាតឲ្យធ្វើការ កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន តាមការស្នើសុំ ។<br>សូម ឯកឧត្តមប្រធាន ឯកឧត្តមអគ្គនាយក ឯកឧត្តមរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេចតាមការគួរ។<br>04.03.24 |
| **យោបល់របស់ឯកឧត្តមរដ្ឋលេខាធិការ** | **យោបល់ប្រធាននាយកដ្ឋាន** |
| ឯកភាព ។<br>**រដ្ឋលេខាធិការ**<br>29/3/24<br>**អ៊ុក_ប្រុជា** | សូម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកសេវាពាណិជ្ជកម្ម ឯកឧត្តមរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។<br>**ដោយគោរព**<br>**សួន_វិជ្ជា** |